# ព្រេងទាក់ទងនឹងបុណ្យភ្ជុំបិណ្ឌ-បណ្តែតដូនតា

---

មានសេចក្តីដំណាលថា មានឈ្មួញសំពៅ ៥០០ ធ្វើដំណើរចេញទៅជួញតាមសមុទ្រ ។ លុះទៅដល់កោះមួយនោះ ជួនជាល្ងាច នឹងធ្វើដំណើរទៅមុខទៀតនឹងស្ទើរ ទើបនាំគ្នាចូលចតសំពៅនៅទីនោះ ។ កោះនោះ ជាកោះដាច់ស្រយាល ឥតមានមនុស្សនៅទេ ហើយពេលយប់ តែងតែមានពួកប្រេតនាំគ្នាដើរមករកស៊ី ។ ពួកប្រេតទាំងនោះ លុះដើរក្រវែលរកអាហារ ឃើញមនុស្សដេកក្នុងសំពៅ ក៏ចាប់មនុស្សកំពុងដេកលក់ យកទៅឲ្យចៅហ្វាយវាខ្លះ គិតនឹងហែកស៊ីខ្លះ ។ ពួកមនុស្សដេកលក់ដោយសារសំឡេងប្រេតនិយាយគ្នា ក៏ភ្ញាក់ឡើង ភ័យស្លុត យំសោកទ្រហឹង ខំអង្វរករដូចម្តេច ក៏ពួកវាពុំព្រម ហើយគិតតែពីចាប់នាំទៅប្រគល់ឲ្យចៅហ្វាយនាយវា ។

សម្រែកយំសោក បណ្តាលឲ្យផ្អើលអស់មនុស្សទាំង ៥០០ សំពៅ ។ ពេលនោះ នាយសំពៅម្នាក់ ជាអ្នកឈ្លាសវៃ នឹកឃើញថា "បើទោះជាត្រូវស្លាប់ ក៏ត្រូវតែហ៊ានប្រថុយនិយាយតវ៉ាឲ្យអស់ចិត្តសិន មិនត្រូវឲ្យគេផ្តាច់ជីវិតទទេៗ ឡើយ" គិតហើយ ក៏តាំងស្មារតីអង់អាច និយាយទៅកាន់ស្តេចប្រេត សូមឲ្យលែងពួកខ្លួន, តែស្តេចប្រេតនោះឆ្លើយថា "យើងនឹងសែងពួកឯងទៅវិញមិនបានទេ ព្រោះពួកយើងស្រេកឃ្លានណាស់ .................. យ៉ាងនេះម្តង បើលែងពួកអ្នកឯងទៅ មិនដឹងកាលណានឹងបានទៀតទេ, ពួកយើងខ្សត់អាហារណាស់ !" ។

នាយឈ្មួញអង្វរថា :

- សុំលោកលែងពួកយើងទាំងអស់វិញចុះ យើងសន្យាថា "នឹងទទួលរកអាហារជូនលោក រាល់ឆ្នាំ លុះត្រាតែអស់ជីវិត, បើលោកពិសាយើងទៅនោះ លោកបានឆ្អែតតែមួយគ្រាប៉ុណ្ណោះ, អំណឹះតទៅ លោកនឹងត្រូវអត់ឃ្លានទៀត, បើពួកយើងសន្យានឹងលោកយ៉ាងនេះ តើលោកយកផ្លូវណា ? លោកសុខចិត្តពិសារូបយើងឲ្យបានតែមួយចម្អែត ឬក៏សុខចិត្តទុកជីវិតពួកយើង ដើម្បីឲ្យទៅរកអាហារជូនលោកវិញ ? ។

ពួកប្រេត ឮសំណើនៃនាយឈ្មួញដូច្នេះ ក៏គិតគ្នាមួយសន្ទុះ ទើបព្រមដោះលែងពួកឈ្មួញ ហើយផ្តាំផ្ញើថា "កាលបើពួកអ្នកបានទៅដល់ស្រុកទេសខ្លួនហើយ កាលណា មានខ្យល់ជំនោរធ្លាក់មកពីទិសឯជើង អ្នកទាំងអស់គ្នា ត្រូវធ្វើក្បូនផ្ទុកធញ្ញជាតិ និងអាហារគ្រប់យ៉ាង មានលាជ, សណ្តែក, ល្ង, ដូង, អំបុក, ចេក ជាដើម បណ្តែតតាមខ្សែទឹកមកឲ្យយើងចុះ មិនបាច់នាំមកផ្ទាល់ទេ, ជំនោរខ្យល់ នឹងបញ្ជូនមកដល់យើងហើយ" ។

ឮតែប៉ុណ្ណោះ ពួកអ្នកសំពៅ អររកអ្វីប្រៀបពុំបាន ហើយក៏នាំគ្នាចុះសំពៅរចាករចល់ខ្សៀវខ្សារ បើកចេញផុតពីនោះយ៉ាងប្រញាប់ ។ លុះទៅដល់ភូមិស្រុក ជួបជុំគ្រួសារហើយ ត្រូវនឹងពេលជិតដល់រដូវភ្ជុំ ដែលទឹកឡើងជាលំដាប់ផង អ្នកដែលបានសន្យានឹងប្រេតទាំងនោះ ក៏នាំគ្នាធ្វើនំនែក រកចេកអំពៅ លាជ ស្រូវ អង្ករ ផ្លែឈើ ដែលមានក្នុងរដូវនោះ ធ្វើពោង

ពាយ ហើយដាក់បណ្ដែតបញ្ជូនទៅឲ្យប្រេតតាមខ្សែទឹករាល់ៗ ឆ្នាំ ។ មនុស្សជាន់ដើម កាន់ពាក្យសច្ចៈល្អណាស់ បើនិយាយសន្យាថាដូចម្ដេចហើយ មិនហ៊ានបំពានទេ ។

ចំណេរតមក អ្នកស្រុក ក៏នាំគ្នាធ្វើតៗ មក ទៅជាទំនៀមទម្លាប់ ដោយយល់ថា "ធ្វើបុណ្យបណ្ដែតស្រូវអង្ករទៅឲ្យដូនតាដែលទៅកើតជាប្រេត បិតនៅឯស្រុកទន្លេស្ងួត កន្ទួតមួយដើម" នោះវិញ ។